**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់**

លេខ : ១២៥ស.ស.រ.

# សេចក្តីសម្រេច
## ស្តីពី
## ការបង្កើតក្រុមការងារទទួលជួប សម្របសម្រួល និងដោះស្រាយជាមួយក្រុមអ្នកតវ៉ា ឬក្រុមបាតុករពាក់ព័ន្ធនឹងបញ្ហាដីធ្លី

## ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦៩៩/០៩ ចុះថ្ងៃទី២៣ ខែមិថុនា ឆ្នាំ១៩៩៩ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- បានឃើញអនុក្រឹត្យលេខ ៦២ អនក្រ.បក ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៩ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួងរៀបចំដែនដី នគរូបនីយកម្មនិងសំណង់
- យោងតាមការចាំបាច់របស់ក្រសួង

## សម្រេច

**ប្រការ១._**

ត្រូវបានបង្កើតក្រុមការងារទទួលជួប សម្របសម្រួល និងដោះស្រាយជាមួយក្រុមអ្នកតវ៉ាឬក្រុមបាតុករពាក់ព័ន្ធនឹងបញ្ហាដីធ្លី ដែលមានសមាសភាពដូចខាងក្រោម :

| | | |
|---|---|---|
| ១-ឯកឧត្តម **លឹម ទាន់** | រដ្ឋលេខាធិការ | ប្រធាន |
| ២-ឯកឧត្តម **ទេព ធន** | អនុរដ្ឋលេខាធិការ | អនុប្រធាន |
| ៣-ឯកឧត្តម **ឡោ ដាឌុធ** | អគ្គនាយកនៃអគ្គនាយកដ្ឋានសុរិយោដី និងភូមិសាស្ត្រ | សមាជិក |
| ៤-ឯកឧត្តម **ហង្ស សុតសំភារ** | អគ្គនាយករងនៃអគ្គនាយកដ្ឋានសំណង់និងជាអគ្គលេខាធិការរងនៃ គ.អ.ធ.ក | សមាជិក |
| ៥-លោក **សេង ឡូត** | អគ្គនាយករដ្ឋបាលស្តីទី | សមាជិក |
| ៦-លោក **ឌុឡី ចណ្ណារ៉ា** | អគ្គនាយករងនៃអគ្គនាយកដ្ឋានសុរិយោដីនិងភូមិសាស្ត្រ និងជាប្រធានលេខាធិការដ្ឋាន គណៈកម្មការសុរិយោដីថ្នាក់ជាតិ | សមាជិកអចិន្ត្រៃយ៍ |
| ៧-លោក **កុសល សុពិនត្ស** | ប្រធាននាយកដ្ឋាននីតិកម្ម | សមាជិក |



អាសយដ្ឋាន : លេខ ៧៧១-៧៧៣ មហាវិថីព្រះមុនីវង្ស សង្កាត់បឹងត្របែក ខណ្ឌចំការមន រាជធានីភ្នំពេញ
Tel / Fax : 023 215 279 / (855-23) 215 660 / 023 217 031 គេហទំព័រ www.mlmupc.gov.kh /

| | | |
|---|---|---|
| ៨-លោក ឡាយ ផល្លីម | ប្រធាននាយកដ្ឋានរដ្ឋបាលនិងកិច្ចការទូទៅ | សមាជិក |
| ៩-លោក ចេង ស្រុង | ប្រធាននាយកដ្ឋានអធិការកិច្ចភូមិបាល | សមាជិក |
| ១០-លោក សយ ឃោសាភា | ប្រធាននាយកដ្ឋានផែនការ សេដ្ឋកិច្ច និងហិរញ្ញកិច្ច | សមាជិក |
| ១១-លោក អេ ម៉ុនធឿន | អនុប្រធាននាយកដ្ឋានអភិវឌ្ឍន៍សេដ្ឋកិច្ច កិច្ចការវិនិយោគនិងទំនាក់ទំនងអន្តរជាតិ និងជាអនុប្រធានលេខាធិការដ្ឋានគណៈកម្មការសុរិយោដីថ្នាក់ជាតិ | លេខាធិការ |

**ប្រការ ២._**

ក្រុមការងារមានភារកិច្ច ៖

១- ទទួលជួបក្រុមអ្នកតវ៉ា ឬក្រុមបាតុករ។

២- ទទួលញត្តិនិងឯកសារពាក់ព័ន្ធនានាពីក្រុមអ្នកតវ៉ា ឬក្រុមបាតុករ ។

៣- សម្របសម្រួល និងដោះស្រាយជាមួយក្រុមអ្នកតវ៉ា ឬក្រុមបាតុករ។

៤- ស្នើវិធានការដោះស្រាយដើម្បីសុំការសម្រេចពីក្រសួង។

៥- ទំនាក់ទំនងជាមួយក្រុមអ្នកតវ៉ាឬក្រុមបាតុករដើម្បីទទួលបានព័ត៌មានបន្ថែម និងជូនដំណឹងអំពីដំណោះស្រាយ។

៦- តាមដានការអនុវត្តវិធានការក្នុងការដោះស្រាយរហូតដល់ករណីវិវាទត្រូវបានបញ្ចប់ជាស្ថាពរ និងធ្វើរបាយការណ៍ជូនក្រសួងអំពីវឌ្ឍនភាពនៃការដោះស្រាយជាជំហានៗ។

៧- ធ្វើរបាយការណ៍លទ្ធផលប្រចាំត្រីមាស ឆមាស និងប្រចាំឆ្នាំ ជូនក្រសួង។

**ប្រការ ៣._**

សមាជិកក្រុមការងារត្រូវចូលរួមប្រជុំតាមការអញ្ជើញរបស់ប្រធាន ។

**ប្រការ ៤._**

ក្រុមការងារអាចប្រើប្រាស់មន្ត្រីក្រោមឱវាទ ឲ្យជួយការងារតាមការចាំបាច់។

**ប្រការ ៥._**

នាយកខុទ្ទកាល័យ អគ្គនាយកគ្រប់អគ្គនាយកដ្ឋាន គ្រប់ប្រធាននាយកដ្ឋាន និងអង្គភាពពាក់ព័ន្ធ និងឯកឧត្តម អស់លោក ដូចរាយនាមក្នុងប្រការ ១ ត្រូវអនុវត្តសេចក្តីសម្រេចនេះឲ្យមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ។

ថ្ងៃសុក្រ ០២រោច ខែចេត្រ ឆ្នាំមមែ ព.ស.២៥៥៩
រាជធានីភ្នំពេញ ថ្ងៃទី០៨ ខែមេសា គ.ស. ២០១៦
ទេសរដ្ឋមន្ត្រី
រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់

ជា សុផារ៉ា

**កន្លែងទទួល**
- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងមហាផ្ទៃ
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- ក្រសួងមុខងារសាធារណៈ
- គ្រប់សាលារាជធានី ខេត្ត
- គ្រប់មន្ទីរ ដនសស រាជធានី ខេត្ត
- ដូចប្រការ ៥
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ